ប័ណ្ណពត៌មាន 3

# រក្សាវាឲ្យបានស្អាតសំរាប់ទីវាលដាំបន្លែ

## រុក្ខជាតិដែលជាប្រភពនៃសត្វចង្រៃ និងជម្ងឺ

Virginia Brunton & Jeremy Badgery-Parker, Ourimbah

### រុក្ខជាតិដែលជាប្រភពនៃសត្វចង្រៃ

ជំណាក់កាលទីមួយនៃការកាត់បន្ថយហានិភ័យ ដែលកើតឡើងដោយសារសត្វចង្រៃ (ឧទាហរណ៍ សត្វល្អិត សត្វចៃ រុក្ខជាតិតូចៗឥតប្រយោជន៍ ជម្ងឺដោយសារសត្វព្រូន) គឺការយល់ច្បាស់អំពីប្រភពសត្វចង្រៃដែលជារុក្ខជាតិ និងប្រភពដែលពុំមែនជារុក្ខជាតិ នៅក្នុង និងជុំវិញដំណាំដែលជាកន្លែងវាអាចចេញមកបាន។ រុក្ខជាតិ និងបំណែករុក្ខជាតិទាំងអស់ដែលនៅជុំវិញដំណាំ អាចជាប្រភពនៃសត្វចង្រៃ។

**រុក្ខជាតិតូចៗឥតប្រយោជន៍** គឺជាប្រភពមួយយ៉ាងសំខាន់បំផុតនៃសត្វល្អិតចង្រៃ សត្វចៃ និងជម្ងឺ។ មានហានិភ័យកំរិតខ្ពស់ដែលថាសត្វចង្រៃនឹងចូលមកក្នុងដំណាំរបស់លោកអ្នកតាមរយះរុក្ខជាតិតូចៗឥតប្រយោជន៍ ដែលនៅក្នុង និងជុំវិញដំណាំរបស់លោកអ្នក។ រុក្ខជាតិតូចៗឥតប្រយោជន៍ផ្តល់ជាជំរក និងអាហារសំរាប់សត្វល្អិតចង្រៃ និងចៃ ហើយធ្វើជាកន្លែងសំរាប់បង្ករបង្កើតជម្ងឺ។

> *“ ត្រូវថែរក្សាកន្លែងដាំដំណាំ និងចំការដែលនៅជុំវិញកុំឲ្យមានរុក្ខជាតិតូចៗឥតប្រយោជន៍ ”*

មានរុក្ខជាតិច្រើនប្រភេទ ដែលផ្តល់កន្លែងជ្រកកោនដល់សត្វចង្រៃនៅជុំវិញចំការ។ ជាទូទៅ រុក្ខជាតិណាមួយដែលនៅក្នុងអម្បូររុក្ខជាតិ ដូចដំណាំដែលលោកអ្នកកំពុងដាំ គួរបានចាត់ទុកជាប្រភពនៃសត្វចង្រៃ (ឧទាហរណ៍ blackberry nightshade ដែលនៅក្នុងអម្បូររុក្ខជាតិដូចគ្នានឹង ប៉េងប៉ោះ និងម្ទេសផ្លោក)។ រុក្ខជាតិដែលសម្បូណ៌ដោយផ្កា ជាទូទៅផ្តល់កន្លែងជ្រកកោនដល់សត្វចង្រៃមួយចំនួន ជាពិសេសសត្វល្អិតចង្រៃហៅថា thrips។

វ៉ាយរឹសរបស់ដំណាំជាច្រើនមានកន្លែងរស់នៅផ្សេងទៀត ក្នុងរុក្ខជាតិតូចៗ ឥតប្រយោជន៍ ហើយកន្លែងនោះរួមផ្សំជាមួយនឹង vector (សត្វល្អិតចង្រៃម្យ៉ាងដែលនាំជម្ងឺឆ្លង) ដែលសមស្របគ្នា អាចជាប្រភពនៃការឆ្លងជម្ងឺ។

រុក្ខជាតិតូចៗឥតប្រយោជន៍អាចធ្វើជាស្ពានចម្លង រវាងដំណាំដែលដាំដាច់ដោយឡែកពីគ្នា។

**ដំណាំដទៃទៀត** ដែលនៅលើចំការលោកអ្នក និងលើដីកម្មសិទ្ធិជិតខាងចាំបាច់ត្រូវចាត់ទុកជាហានិភ័យចំពោះដំណាំរបស់លោកអ្នក។ ការនេះសំខាន់ជាពិសេស ប្រសិនបើដំណាំដែលនៅក្បែរៗគ្នា ឋិតក្នុងអម្បូររុក្ខជាតិដូចគ្នានឹងដំណាំដែលលោកអ្នកកំពុងដាំ ពីព្រោះវាអាចផ្តល់កន្លែងរស់នៅដល់សត្វចង្រៃដែលនឹងប៉ះពាល់ដល់ដំណាំរបស់លោកអ្នក។ គឺជាការមានប្រយោជន៍ដែលដឹងថា តើដំណាំអ្វីខ្លះទៀតដែលផ្តល់កន្លែងរស់នៅចំពោះសត្វល្អិតចង្រៃដ៏សំខាន់ ជម្ងឺ និងសត្វព្រូន។ ឧទាហរណ៍ វ៉ាយរឹសនៃជម្ងឺ spotted wilt លើផ្លែប៉េងប៉ោះ សត្វល្អិតចង្រៃឈ្មោះ western flower thrips និងជម្ងឺ Sclerotinia (ជម្ងឺដុះផ្សិតដែលបង្ករឡើងដោយដី) ដែលធ្វើឲ្យខូចខាតដល់ដំណាំផ្សេងៗឯទៀតជាច្រើន។

### ការដាំបំបែករវាងដំណាំ

ធញ្ញជាតិទោរទន់ចង់តែផ្តល់កន្លែងរស់នៅ ដល់សត្វចង្រៃបំផ្លាញបន្លែមួយចំនួនតូច និងជាដំណាំដ៏ល្អសំរាប់ដាំបំបែកដំណាំឯទៀត ឬមានប្រយោជន៍សំរាប់ដាំនៅក្នុងកន្លែងដែលគ្មានការដាំដុះ។ តាមរបៀបដូចគ្នានេះដែរ រុក្ខជាតិក្នុងស្រុកនៃប្រទេសអូស្ត្រាលីជាច្រើន មានប្រយោជន៍សំរាប់ដាំនៅក្នុងកន្លែងដែលគ្មានការដាំដុះ និងកាត់បន្ថយសេចក្តីត្រូវការសំរាប់ការគ្រប់គ្រងលើរុក្ខជាតិតូចៗឥតប្រយោជន៍។



*ស្លឹកឈើ និងផ្លែឈើដែលគេបោះចោល ផ្តល់ជាកន្លែងជ្រក កោនដល់សត្វល្អិតចង្រៃ និងជម្ងឺ*

**កំទេចសំណល់ដំណាំ** អាចឲ្យកន្លែងជ្រកកោនសំរាប់សត្វចង្រៃជាច្រើន ផ្តល់ ឲ្យវានូវកន្លែងផុតគ្រោះថ្នាក់ដើម្បីរង់ចាំនៅម្តុំជុំវិញ មុននឹងផ្លូវកន្លែងទៅក្នុង ដំណាំដទៃមួយទៀត។ កំទេចសំណល់ដំណាំ មានរួមទាំងរុក្ខជាតិចាស់ៗ ដែលគេយកចេញពីដំណាំ ក៏ដូចជាមែកឈើដែលគេកាត់ចោល និងបំណែករុក្ខជាតិដែលគេយកចេញពីដំណាំ ក្នុងកំឡុងកាលរីកលូតលាស់ដែរ។ ផ្លែឈើចាស់ៗដែលទុកចោលក្នុងដំណាំ អាចផ្តល់ជាកន្លែងឥតគ្រោះថ្នាក់សំរាប់សត្វចង្រៃ រហូតដល់ដំណាំថ្មីបានដុះឡើងនៅក្បែរគ្នា។

**ដំណាំចាស់ៗ** ជាពិសេសដំណាំទាំងនោះដែលនៅជិតដំណាំថ្មី អាចឲ្យទីជ្រកពួនដល់សត្វចង្រៃមួយចំនួន និងជម្ងឺផងដែរ។ រុក្ខជាតិណាមួយដែលនៅក្នុង ឬក្បែរដំណាំរបស់លោកអ្នក គឺជាប្រភពមួយចំនួនសំខាន់បំផុតរបស់សត្វចង្រៃ និងអាចទុកសម្រាប់ឲ្យសត្វចង្រៃភាគច្រើនឆ្លងចូលទៅក្នុងដំណាំថ្មី។

> *“ត្រូវដាក់កូនរុក្ខជាតិតូចៗទាំងអស់ឲ្យនៅដាច់ពីគេ ដើម្បីបង្ការការឆ្លងរោគ និងឆែកមើលឲ្យដឹងថា កូនរុក្ខជាតិតូចៗទាំងនោះពុំមានសត្វចង្រៃ និងជម្ងឺឡើយ មុននឹងដាំបណ្តុះវា”*

> *“ដាំបណ្តុះដំណាំចាស់ៗទៅក្នុងដីជាបន្ទាន់ ក្រោយពេលច្រូតកាត់ប្រមូលផលរួច ឬត្រូវបោះបង់វាចោល ”*

**សំណល់ដំណាំក្រោយការច្រូតកាត់ប្រមូលផល ឬដំណាំដែលគេបោះបង់ចោល** គឺជាទីលានដ៏ឧត្តមសំរាប់ចិញ្ចឹមសត្វចង្រៃ។ គឺជាការសំខាន់ដែលដាំបណ្តុះសំណល់ដំណាំនៅក្នុង ឬដំណាំដែលគេបោះបង់ចោលឲ្យបានឆាប់តាមលទ្ធភាពធ្វើបាន ក្រោយពេលដំណាំបានច្រូតកាត់ប្រមូលផលរួច។ ប្រសិនបើដំណាំទាំងនេះមានសត្វល្អិតចង្រៃច្រើន ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតឲ្យបានត្រឹមត្រូវមុនពេលដាំបណ្តុះ នឹងកាត់បន្ថយភាពអាចមានសត្វចង្រៃប្តូរកន្លែងទៅនៅក្នុងរុក្ខជាតិ ឬដំណាំឯទៀត។

**រុក្ខជាតិសំរាប់ប្រើផ្ទាល់ខ្លួន ឬរុក្ខជាតិតូចៗ** ដូចជាជីរដែលគេប្រើម្តងម្កាលដុះនៅខាងចុងរងដំណាំ មានលក្ខណៈដូចគ្នានឹងរុក្ខជាតិតូចៗឥតប្រយោជន៍ដែរ។ រុក្ខជាតិទាំងនេះអាចធ្វើជាប្រភពសត្វចង្រៃ ហើយពុំគួរដាំជាមួយដំណាំសំរាប់ធ្វើជំនួញឡើយ។

ទីកន្លែងផលិតភោគផលនីមួយៗ ចាំបាច់ត្រូវប្រើសម្រាប់ “ដំណាំតែមួយប្រភេទគត់”។ ការនេះមានន័យថារុក្ខជាតិទាំងអស់ដែលមាននៅក្នុងកន្លែងមួយចាំបាច់ត្រូវមានប្រភេទដូចគ្នា និងអាយុដំណាលគ្នា។

**កូនរុក្ខជាតិតូចៗ** គឺជាប្រភពសំខាន់របស់សត្វល្អិតចង្រៃ និងជម្ងឺ។ កូនរុក្ខជាតិតូចៗបានមកពីក្រៅកន្លែងផលិតភោគផលដំណាំរបស់លោកអ្នក ឬមកពីកន្លែងដាំបណ្តុះរុក្ខជាតិឲ្យបានច្រើនរបស់លោកអ្នកខ្លួនឯង ឬមកពីកន្លែងបណ្តុះ និងលក់ដើមឈើ។ ការនេះមានន័យថាកូនរុក្ខជាតិតូចៗទាំងនោះគឺជាប្រភពដ៏ខ្លាំងក្លារបស់សត្វចង្រៃ ដែលចូលទៅក្នុងដំណាំរបស់លោកអ្នក។

ការទទួលស្គាល់: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ បានរៀបចំចេញពីរក្សាវាឲ្យបានស្អាត – កាត់បន្ថយការចំណាយ និងការខាតបង់ក្នុងការគ្រប់គ្រងសត្វចង្រៃ និងជម្ងឺនៅក្នុងរោងដាំបន្លែ និងកូនរុក្ខជាតិ។ Badgery-Parker, J and T Burfield 2009 ជាមួយនឹងគំនិត និងឱវាទបានមកពី Sandra McDougall និង Alison Anderson។

© រដ្ឋញូវសៅវែល តាមរយៈក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ ឆ្នាំ២០១០។ លោកអ្នកអាចចម្លង ចែកចាយ និងដោះស្រាយជាមួយនឹងការបោះពុម្ពផ្សាយតាមរបៀបផ្សេងពីនេះដោយសេរី ដើម្បីគោលបំណងណាមួយ គឺឲ្យតែលោកអ្នកបានបញ្ជាក់ថាក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ គឺជាម្ចាស់កម្មសិទ្ធិនៃការបោះពុម្ពផ្សាយនេះ។

ISSN 1832-6668

ការប្រកាសមិនទទួលខុសត្រូវ: ពត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ គឺសំអាងលើចំណេះដឹង និងការយល់ដឹងនៅក្នុងពេលកំពុងសរសេរ (ខែមីនា ឆ្នាំ២០១២)។ ទោះជាយ៉ាងនេះក្តី ដោយសារការជឿនលឿនផ្នែកចំណេះដឹង អ្នកប្រើប្រាស់ត្រូវបានរំលឹកអំពីសេចក្តីត្រូវការដើម្បីឲ្យប្រាកដច្បាស់ថា ពត៌មានដែលគេពឹងផ្អែកទៅលើមានលក្ខណៈទាន់ពេល និងសំរាប់ឆែកមើលបច្ចុប្បន្នភាពនៃពត៌មានជាមួយភ្នាក់ងារសមស្របរបស់ក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ឬអ្នកផ្តល់ឱវាទឯករាជ្យសំរាប់អ្នកប្រើប្រាស់។

ចុះផ្សាយដោយក្រសួងឧស្សាហកម្មកែឆ្នៃវត្ថុធាតុដើម ដែលជាផ្នែកមួយរបស់ក្រសួងពាណិជ្ជកម្ម និងវិនិយោគ ហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់ និងកិច្ចបំរើ។

Trim reference INT 12/24526

ការផលិតប័ណ្ណពត៌មាននេះ និងការបកប្រែភាសាបានទទួលការផ្គត់ផ្គង់ប្រាក់មួយចំណែក ពីគំរោងដែលទទួលប្រាក់ឧបត្ថម្ភរបស់ HAL អង្គការដំណាំវប្បកម្មអូស្ត្រាលី): *ការដោះស្រាយអំពីគុណភាព និងសុវត្ថិភាពនៃផលិតផលជាមួយអ្នកដាំដុះនៃឧស្សាហកម្មបន្លែ ដែលនិយាយភាសាក្រៅពីភាសាអង់គ្លេស* ការផ្តើមគំនិតនៃកម្មវិធីអភិវឌ្ឍន៍ឧស្សាហកម្មបន្លែ។